ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំស្វាយ



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ

ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៦






**អាសយដ្ឋាន** : អគារលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**

# សៀវភៅ

# ស្តីពី

# ដំណាំស្វាយ


## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម



បោះពុម្ពលើកទី១ ចំនួន ២០០០ច្បាប់

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្ដីពីដំណាំស្វាយ

## I. ទីប្រឹក្សាផ្ដល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម
២. បណ្ឌិត **ម៉ៅ មីនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៣. លោក **ប៉ែន ឧុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៣. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## III. ក្រុមការងារស្រាវជ្រាវ:

១. លោក **នូ ប្រណិត** មន្ទីរកសិកម្មខេត្តបាត់ដំបង
២. លោក **វ៉ាត គឹមជាង** មន្ទីរកសិកម្មខេត្តកំពង់ធំ

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **ពេជ សុខន្ធារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
២. លោក **ហុង វុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៣. លោកស្រី **ចាន់ សុធី** នាយកដ្ឋានសាវប្បកម្ម និងដំណាំរួមផ្សំ
៤. លោក **កេត សំអាត** នាយកដ្ឋានសាវប្បកម្ម និងដំណាំរួមផ្សំ





## មាតិកា ទំព័រ


១. បច្ចេកទេសរៀបចំរណ្តៅ.............................០២

២. បច្ចេកទេសដាំ..........................................០៣

៣. បច្ចេកទេសថែទាំ និងដាក់ជី.......................០៤

៤ . បច្ចេកទេសស្រោចទឹក...............................០៥

៥. បច្ចេកទេសកាត់តែងមែក............................០៥

៦. បច្ចេកទេសធ្វើឱ្យស្វាយចេញផ្កា...................១០

៦. បច្ចេកទេសបំបាត់មេរោគ និងសត្វល្អិតបំផ្លាញ
ដំណាំ......................................................១៧

៧. បច្ចេកទេសប្រមូលផល..............................១៨



# ដំណាំស្វាយ

ជាទូទៅ គេនិយមដាំស្វាយលើដី ដោយធ្វើការលើករង សម្រាប់តំបន់វាលទំនាប មានទឹកលិច ពេលមានជំនន់ទឹកភ្លៀង ឬទឹកទន្លេ។ ចំណែកឯនៅតំបន់ភូមិភាគឥសាន្ត និងឧត្តរ ជាទីកន្លែងដែលគ្មានទឹកជំនន់ គេក៏អាចដាំស្វាយបានដែរ នៅលើដីតាមតំបន់ទួល ក៏ប៉ុន្តែសម្រាប់ការដាំដុះស្វាយនៅតាមតំបន់ខ្ពង់រាបនេះ គឺមានតិចប៉ុណ្ណោះសម្រាប់ប្រទេសកម្ពុជា។

ផ្អែកលើលក្ខខណ្ឌទាំងពីរខាងលើ ការដាំដំណាំស្វាយត្រូវបានចែកចេញជាពីរផ្នែក ដាច់ដោយឡែកពីគ្នាដូចខាងក្រោម៖

១- ការដាំលើដី ដោយធ្វើការលើករង (តំបន់ទំនាប)

២- ការដាំលើដីទួល(តំបន់ខ្ពង់រាប)



*ដំណាំស្វាយដាំនៅតំបន់វាលទំនាប*



*ដំណាំស្វាយដាំនៅតំបន់ខ្ពង់រាប*

ដោយប្រទេសកម្ពុជា ប្រជាកសិករភាគច្រើន និយមរស់នៅតាមតំបន់វាលទំនាបជាពិសេសតាមដងទន្លេ ហើយនិយមដាំស្វាយ ដោយធ្វើការលើក

វង ដូច្នេះសៀវភៅនេះសូមលើកយកតែវិធីទី១ មករៀបរៀងដើម្បីជាជំនួយស្មារតីផ្នែកបច្ចេកទេសបន្ថែម ជូនដល់បងប្អូនប្រជាកសិករ និងអ្នកពាក់ព័ន្ធជាប្រយោជន៍ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មឱ្យមានការអភិវឌ្ឍបន្ថែមទៀត។

ចម្ការស្វាយភាគច្រើន មាននៅក្នុងតំបន់វាលទំនាប ដោយសារតំបន់ទាំងនោះ ជាតំបន់ដែលមានដីលក្ខណៈដីឥដ្ឋ និងល្បាយខ្សាច់ច្រើន។ ការដុះលូតលាស់នៃដំណាំស្វាយ នៅលើដីឥដ្ឋ មានសភាពយឺតជាងដំណាំស្វាយដាំនៅលើដីល្បាយខ្សាច់ ឬដីមានជីជាតិល្អ ។

## ១. បច្ចេកទេសរៀបចំរណ្តៅ:

- ត្រូវជីករណ្តៅ ៨តឹកបួនជ្រុង( ០,៨ ម៤ជ្រុង ) និងជំរៅ៨តឹក( ០.៨ម )
- រោយកំបោរសប្រមាណ២ស្លាបព្រាបាយ ក្នុង១រណ្តៅ។
- ត្រូវដាក់ផេះអង្កាម កំប្លោក ចំបើងពុក លាមកគោ មាន់ ជ្រូកដែលពុកផុយរលួយ មួយស្រទាប់កម្រាស់ ១តឹក( ០,១ម រួចដាក់ដីពីលើ ១តឹក( ០,១ម )យើងធ្វើយ៉ាងនេះ រហូតពេញរណ្តៅ។
- ត្រូវទុករណ្តៅដែលរៀបចំហើយក្នុងរយៈពេល ២ ទៅ ៣អាទិត្យ។



- សម្រាប់ស្វាយកែវចិនចម្ងាយពីរណ្តៅមួយទៅរណ្តៅមួយមានប្រវែង ៨ ម៉ែត្រ។
- សម្រាប់ស្វាយកែវរមៀតចម្ងាយពីរណ្តៅមួយទៅរណ្តៅមួយមានប្រវែង ៥-៦ ម៉ែត្រ។




## ២. បច្ចេកទេសដាំ:

- កូនស្វាយត្រូវរក្សាផ្សាំទុករយៈពេល ១អាទិត្យមុនដាំ
- ផ្អាកការស្រោចទឹក២ថ្ងៃមុនដាំ ដើម្បីកុំឱ្យបែកដី និងដាច់ឫស។



- មុនដាំត្រូវជញ្ជូនកូនស្វាយដាក់ក្បែររណ្តៅទាំងអស់។
- ត្រូវហែកបកថង់ចេញកុំឱ្យបែកដី។
- ដាក់កូនស្វាយចូលក្នុងរណ្តៅ រួចកប់ក្នុងអាចម៍ដី ប្រហែល ១ តឹក (០,១ម) ក្រោមមាត់រណ្តៅ។
- លប់ដីដោយសង្កត់ថ្នមៗ រួចយកមែកឈើដោតក្បែររណ្តៅចងទប់ជាមួយ កូនស្វាយ។

## ៣. បច្ចេកទេសថែទាំ និងដាក់ជី:

- ខែវស្សាត្រូវពូនគល់ការពារទឹកលិច។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើជីលាមកមាន់ អាចម៍ជ្រូកលាយជាមួយផេះអង្កាម ចំបើង ឬកំប្លោកកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនស្វាយមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសម្លាប់សត្វល្អិត ឬថ្នាំ កាបារីល (Carbaryl) S85 សម្រាប់ជំនួយស្លឹក និងដើមលូតលាស់ល្អ។

## ជីសរីរាង្គ

ជីសរីរាង្គមានបួនប្រភេទផ្សេងៗគឺ ៖



- លាមកសត្វ



- ជីកំប៉ុស្ដ



- សំរាមគ្រប់ជីវិញ្ញផល់



- ជីបៃតង